**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការពារជាតិ**

លេខ : ០២៦ / ស.ស.រ / ២០០៤

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៤

## សេចក្ដីសំរេច
## ស្ដីពី
## ការបង្កើតផ្លាកសញ្ញាបន្ថែម សំរាប់បិទលើទោចក្រយានយន្ត កងឯកភាពកងរាជអាវុធហត្ថ

## សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២ ន.ស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រមលេខ ន.ស/រកត/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងការពារជាតិ ។
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៤ ស្ដីពីភារកិច្ច និងរចនាសម្ព័ន្ធទូទៅ នៃកងរាជអាវុធហត្ថ ។
- យោងអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៣ ស្ដីពីការកែសំរួលផ្លាកសញ្ញាឋានន្តរសក្ដិ សញ្ញាកងឯកភាពឆត្រយោង ឯកសណ្ឋានការងារលេខ៤ មួកបេរ៉េ ការស្លៀកពាក់ឯកសណ្ឋានការងារលេខ៤ និងសញ្ញា អត្តសញ្ញាណ កងទ័ពជើងគោក ជើងទឹក ជើងអាកាស និងរូបសញ្ញាក្រសួងការពារជាតិ ។
- យោងអនុក្រឹត្យលេខ ២៦ អនក្រ ចុះថ្ងៃទី ០៨ ខែឧសភា ឆ្នាំ១៩៩៨ ស្ដីពីឯកសណ្ឋាន និង ផ្លាកសញ្ញាកងរាជអាវុធហត្ថ ។

## សំរេច

**ប្រការ១** : ត្រូវបានបង្កើតផ្លាកសញ្ញាបន្ថែមសំរាប់បិទទោចក្រយានយន្តរបស់កងឯកភាព កងរាជអាវុធហត្ថ ដូចខាងក្រោម៖

**ក- រូបរាងផ្លាកសញ្ញា**

- ផ្នែកខាងលើមានចារិកអក្សរ ( កងរាជអាវុធហត្ថ ) ពណ៌ទឹកប៊ិច ។

benkry 2

- ផ្នែកកណ្តាលមានអក្សរកាត់ធំ១ពីរតួ ពណ៌ទឹកប៊ិច ( អ.ហ ) ។
- សងខាងអក្សរ អ.ហ មានស្លាបបីថ្នាក់ ពណ៌ទឹកប៊ិច ។
- ផ្នែកខាងក្រោមមានសរសេរជាអក្សរបារាំង ហ្សង់ដាមមើរីពណ៌ទឹកប៊ិច(GENDARMIERIE) ។

**ខ- ខ្នាត និងការប្រើប្រាស់ផ្លាកសញ្ញា**

- ខ្នាតតូច មានបណ្តោយទំហំ ២៤សម កំពស់ ៩.៧៥សម សំរាប់បិទលើធុងសាំង ។
- ខ្នាតធំ មានបណ្តោយទំហំ ៣២សម កំពស់ ១៣សម សំរាប់បិទលើរបាំងខាងមុខ ។

**ប្រការ២ :** នាយក ខុទ្ទកាល័យក្រសួងការពារជាតិ មេបញ្ជាការកងរាជអាវុធហត្ថ អង្គភាព ស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តន៍សេចក្តីសំរេចនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានិងឡាយព្រហស្តលេខានេះតទៅ ។

**ចម្លងជូន**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គបញ្ជាការដ្ឋាន ខ.ភ.ម
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ✓

" **ដើម្បីជូនជ្រាប** "
- ឯកសារ-កាលប្បវត្តិ

សហរដ្ឋមន្ត្រី

នាយឧត្តមសេនីយ៍ ទៀ-បាញ ស៊ីសុវត្ថិ-សិរីរ័ត្ន




## សំរាប់បិតធុងសាំង




## សំរាប់បិតកញ្ចក់មុខ






